# សហព័ន្ធខ្មែរកម្ពុជាក្រោម

KHMERS KAMPUCHEA-KROM FEDERATION
ASIA – AUSTRALIA – EUROPE – NORTH AMERICA
A MEMBER OF UNPO & IDBF
**Office of President:** P.O. Box 39084 • London • ON • N5Y-5L1 • CANADA. Tel/Fax: (519) 659-3920
www.khmerkrom.org . www.khmerkrom.net . Email: thach.thach@khmerkrom.org

ធ្វើនៅទីក្រុងឡុនដុន ខេត្តអនតារីយ៉ូ
ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០០៧
សួស្តី ឆ្នាំ ២០០៨

យើងខ្ញុំសូមគោរព និងសួរសុខទុក្ខមកដល់បងប្អូនជនរួមឈាមហោហិតទាំងអស់ជាទីរាប់អាន!

ក្នុងឱកាសចូលឆ្នាំថ្មីសកលមកដល់ យើងខ្ញុំសូមថ្វាយបង្គំព្រះថេរា~នុត្ថេរៈគ្រប់ព្រះអង្គ និងជនរួមឈាមទូទាំងសកលជាទីគោរព ស្មោះស្មគ្រ័ពីចម្ងាយដោយក្តីនឹករលឹក សូមនិមន្តជ្រាប នឹង អញ្ជើញជ្រាប ។

ឆ្នាំ២០០៧ បានកន្លងផុតទៅ ឆ្នាំ២០០៨បានចូលមកដល់ ដើម្បីជំនួសនូវកាលវេលាដែលបន្តទៅមុខ ។ រីឯចំណារប្រវត្តិសាស្រ្ត បានកត់ត្រាជិតជាប់គ្រប់ជាតិសាសន៍លើសកលលោក នូវអ្វីដែលមានកើតឡើងទៅតាមសង្គមជាតិរៀងៗខ្លួន ។ ដោយឡែកខ្មែរក្រោមបានឆ្លងកាត់នូវប្រវត្តិសាស្រ្តមួយ ដ៏គួរឱ្យកត់សម្គាល់ក្នុងដំណើរនៃការលូតលាស់ នឹងចលនាតស៊ូខ្មែរក្រោមនាឆ្នាំ២០០៧ ដូចមានខាងក្រោម ÷

១~ធនធានមនុស្ស "បានបង្ហាញនូវភាពសាមគ្គី"

២~ធនធានថវិកា "បានផ្តល់នូវទ្រព្យសម្បត្តិ មានលុយកាសជាដើម"

៣~បានធ្វើឱ្យបងប្អូនខ្មែរយល់ដឹងពីការទុក្ខលំបាកក្នុងភាពរស់នៅក្រោមនឹមអនានិគមកុម្មុយនិស្ត៏

៤~បានចូលរួមស្វាគមន៏និងអបអរសាទរច្បាប់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមឬម្ចាស់ស្រុកដែលមនុស្សមានប្រមាណ៣៧០លាក់នាក់ចង់បានដូចខ្មែរក្រោម ដើម្បីបំរើការតស៊ូទាមទារសិទ្ធិសេរីភាព និងការពារផលប្រយោជន៏ជាតិគេ

៥~បានធ្វើឱ្យបញ្ហាខ្មែរក្រោមក្លាយទៅជាបញ្ហាអន្តរជាតិ និងបានទទួលការយកចិត្តទុកដាក់

ឆ្នាំ ២០០៧ គឺឆ្នាំដែលខ្មែរក្រោមទូទាំងសកលគួរតែរីករាយនិងអបអរសាទរ ទទួលនូវលទ្ធផលដែលសហពន្ធ័ បានធ្វើជូនជនរួមឈាមនៅកម្ពុជាក្រោម ដែលកើតឡើងដោយការគាំទ្រនិងឧបត្ថម្ភពីខ្មែរក្រោម នឹងខ្មែរគ្រប់ មជ្ឈដ្ឋាន គឺបានជំរុញឲ្យបញ្ហាខ្មែរក្រោមឲ្យក្លាយទៅជាបញ្ហាអន្តរជាតិ ។ ជាពិសេសដោយមានការយកចិត្ត ទុកដាក់របស់សហរដ្ឋអាមេរិក ផ្នែកខាងជំនឿសាសនា និង សិទ្ធិមនុស្ស មួយអន្លើដោយប្រទេសស្រឡាញ់ សន្តិភាព យុត្តិធម៌ និងប្រជាធិបតេយ្យ ។

ខែ មករា ឆ្នាំ ២០០៧ ជាវេទិកាស្ត្រីខ្មែរក្រោម ក្នុងប្រវត្តិសាស្ត្រ ដែលបានប្រឈមមុខបកស្រាយនៅអាថ៌ កំបាំង នៃការរំលោភសិទ្ធិស្ត្រីភេទ ជាមួយនឹងដំណាងស្ត្រីអង្គការសហប្រជាជាតិ ។

សន្និបាតអង្គការសហប្រជាជាតិស្តីពីជនជាតិដើម ជាវេទិកាមួយបានញាំងឲ្យពិភពលោកស្គាល់នូវចរិត្តយួន កុម្មុយនិស្ត៏ ជាងហ្នឹងទៅទៀត អង្គការសិទ្ធិមនុស្សនៅក្រុងស្សឺណែវបានលាតត្រដាងនូវពុតត្បុតនិងអំពើរំ លោភសិទ្ធិមនុស្សយ៉ាងច្បាស់ក្រឡែត អយុត្តិធម៌ដែលខ្មែរក្រោមត្រូវបានជិះជាន់ ។

សហពន្ធ័បានពង្រឹងជំហរក្នុងអង្គការយូអិនភិអូនទាទីក្រុងឡាអេ ជាមួយមន្ត្រីបុគ្គលិកទាំងអស់ និងសមាជិកទាំង ៦៩អង្គការតំណាងឲ្យជាតិទាំងនោះ ។ ការគាំទ្រពីសំណាក់សហភាពអ៊ឺរុប ដោយមានការជំរុញនូវសេចក្តីសំ រេចគាំទ្រសហពន្ធ័លើការតស៊ូអហឹង្សា និងបានធ្វើគំនាបលើរដ្ឋាភិបាលក្រុងហាណូយឲ្យគោរពសិទ្ធិខ្មែរក្រោម។ សកម្មភាពលើទ្វីបទាំង ៤ អាស៊ី អ៊ឺរុប អូសេអានី និងអាមេរិកខាងជើងបានញាំងឲ្យខ្មែរក្រោមទទួលលទ្ធផល ខាងលើ ។ មានកិច្ចការច្រើនណាស់ ហើយមមាញឹកជាទីបំផុតក្នុងឆ្នាំ២០០៧ យើងអាចហៅបានថាជាឆ្នាំ "ស្មារតីជាតិ" របស់ខ្មែរក្រោមនឹងជាឆ្នាំ "ខ្មែរសាមគ្គី"។ ការធ្វើបាតុកម្មសាមគ្គីជុំវិញពិភពលោក ដោយមាន ការចូលរួមពីជនរួមឈាមខ្មែរ នឹងបរទេស ដែលស្នេហាសន្តិភាព យុត្តិធម៌ សិទ្ធិមនុស្ស ប្រជាធិបតេយ្យ ។ វិរភាពដ៏ក្លាហានរបស់ព្រះសង្ឃ នឹងបងប្អូនជនរួមឈាមនៅក្នុងស្រុក នឹងកម្ពុជាបានលះបង់ជីវិតទទួលរង នូវទារុណកម្មជាប់គុកច្រវាក់ ដើម្បីសេរីភាព សិទ្ធិមនុស្ស នឹងប្រជាធិបតេយ្យ ។

ដើម្បីឲ្យឆ្នាំ២០០៨នេះ នឹងទទួលបាននូវលទ្ធផលជាទីសង្ឃឹម នៃខ្មែរកម្ពុជាក្រោមក្នុងស្រុក ដូច្នេះកម្លាំងចាំ បាច់ទាំងពីរ គឺកម្លាំងមនុស្ស និងកម្លាំងថវិកា ព្រោះកម្លាំងទាំងនេះបង្ហាញនូវភាពរឹងមាំនៃការតស៊ូ នឹងការ

ចង់បាន ចង់ឃើញរបស់យើង ។ ឆ្នាំ២០០៨ជាឆ្នាំដែលយើងរៀបចំខ្លួនជំរុញគ្រប់ផ្នែក មានការបង្កើតថវិកាពង្រីកចំណេះចេះដឹង ស្រាវជ្រាវគ្រប់ជ្រុងជ្រោយ នៅក្នុងស្រុក លើរាល់អំពើ នៃសកម្មភាពរបស់ក្រុងហាណូយមកលើខ្មែរក្រោម មានជាអាទិ៍ គឺសិទ្ធិមនុស្សលើអនុសញ្ញាដែលរដ្ឋាភិបាលបានចុះហត្ថលេខាមាន សិទ្ធិស្ត្រី សិទ្ធិកុមារ នឹងសិទ្ធិរក្សាបរិដ្ឋាន សិទ្ធិបង្កើតក្រុមនយោបាយ នឹងសិទ្ធិជំនឿសាសនា ។ ល ។

ដោយវៀតណាមត្រូវតែយកច្បាប់សិទ្ធិជនជាតិដើមថ្មីមកអនុវត្ត គឺត្រូវតែខំសិក្សាឲ្យយល់ដឹងគ្រប់វគ្គខ័ន្ធទាំងអស់ ។ ឆ្នាំ២០០៨ ជាគ្រឹះស្ថានឆ្នាំ២០០៩ ដែលជាឆ្នាំកុម្មុយនិស្ត៏ហាណូយត្រូវឆ្លើយនូវទង្វើជិះជាន់មនុស្ស បំភ្លឺសិទ្ធិមនុស្ស  ហើយឆ្នាំ២០០៩ ជាគំរប់ខួបទី៦០នៃការប្រគល់ទឹកដី ដោយខុះច្បាប់របស់រដ្ឋាភិបាលបារាំងឲ្យយួនបារ៍-ដាយ ។

នាឱកាសឆ្នាំ២០០៨នេះ យើងខ្ញុំសូមប្រសិទ្ធិពរ សិរីសួស្តី សុភមង្គល ដល់ព្រះតេជគុណគ្រប់ព្រះអង្គ លោក លោកស្រី សូមបានប្រកបតែសេចក្តីសុខ នឹងសេចក្តីចំរើនជួបជុំបងប្អូន មួលមិត្តជិតឆ្ងាយសប្បាយគ្រួសារ។

ដោយគោរពរាប់អានដ៏ស្មោះអំពីខ្ញុំព្រះករុណាខ្ញុំបាទ

ថាច់ង៉ុងថាច់